ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្ដាល**

សំណុំរឿងរដ្ឋប្បវេណីលេខ: ១២២៧
ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣
សាលក្រមលេខ: ០១២ /ឆ
ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្ដាល

បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២៤ ។

**ចៅក្រម**

លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្ដាល

**ដើមចោទ:** ឈ្មោះ [redacted] **សុធា** ភេទប្រុស ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ០១០៤៧៩៥៥៦(០១) អាសយដ្ឋានស្ថិតនៅផ្ទះលេខ [redacted]។

លោកមេធាវី [redacted] តំណាងដោយអាណត្តិឱ្យដើមចោទ ។

**ចុងចម្លើយ:** ១. ឈ្មោះ [redacted] **តារាពេជ្យ** ភេទប្រុស កើតឆ្នាំ១៩៦៨ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅ [redacted] ។ (ប្ដី)

២. ឈ្មោះ [redacted] **ចាន់ឌី** ភេទស្រី កើតឆ្នាំ១៩៨៥ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅ [redacted] (ប្រពន្ធ)

លោកមេធាវី [redacted] និងលោកមេធាវី [redacted] តំណាងដោយអាណត្តិឱ្យសហចុងចម្លើយ ។

## អង្គហេតុ និងចំណុចវិវាទ

### I- ការទាមទាររបស់ដើមចោទ:

១. បង្គាប់ឲ្យ សហចុងចម្លើយ សងប្រាក់ដើមចំនួន USD ១៤០,២៨៨.០៤ (ដប់បួនម៉ឺន ពីររយប៉ែតសិបប្រាំបីដុល្លារអាមេរិក និងបួនសេន) ទៅឲ្យដើមចោទ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនិងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២។

២. បង្គាប់ឲ្យ សហចុងចម្លើយ សងប្រាក់ដើមចំនួនUSD ១៣៩,១៥១.០៩ (ដប់បីម៉ឺន ប្រាំបួនពាន់មួយរយហាសិបមួយ ដុល្លារអាមេរិក និងប្រាំបួនសេន) ទៅឲ្យដើមចោទ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក និងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២។

Scanned with CamScanner

៣. បង្គាប់ឲ្យ សហចុងចម្លើយ សងការប្រាក់ ១,៥% ក្នុងមួយខែ លើប្រាក់ដើមចំនួន USD ១៤០,២៨៨.០៤(ដប់បួនម៉ឺនពីររយប៉ែតសិបប្រាំបី ដុល្លារអាមេរិក និងបួនសេន) គិតត្រឹមពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួន ទៅឲ្យដើមចោទ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនិងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២។

៤. បង្គាប់ឲ្យ សហចុងចម្លើយ សងការប្រាក់ ១,៥% ក្នុងមួយខែ លើប្រាក់ដើមចំនួន USD ១៣៩,១៥១.០៩(ដប់បីម៉ឺនប្រាំបួនពាន់មួយរយហាសិបមួយ ដុល្លារអាមេរិក និងប្រាំបួនសេន) គិតត្រឹមពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួន ទៅឲ្យដើមចោទ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក និងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២។

៥.បង្គាប់ឲ្យ សហចុងចម្លើយ សងសំណងការខូចខាត ២៥% ក្នុងមួយឆ្នាំ រាប់គិតចាប់ពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃជម្រះបំណុលចប់សព្វគ្រប់ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនិងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២។

៦. បង្គាប់ឲ្យ សហចុងចម្លើយ សងសំណងការខូចខាត ២៥% ក្នុងមួយឆ្នាំ រាប់គិតចាប់ពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃជម្រះបំណុលចប់សព្វគ្រប់ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតកនិងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២។

៧. បង្គាប់ឲ្យ សហចុងចម្លើយ សងសំណងនៃការខូចខាត សេវាកម្មច្បាប់ និងការខូចខាតផ្លូវចិត្តឲ្យមក ដើមចោទ ចំនួន USD ៤០,០០០ (បួនម៉ឺនដុល្លារអាមេរិកគត់) ។

៨. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ សហចុងចម្លើយ ។

៩. ប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្នចំពោះការទាមទារខាងលើ ។

II- **ការអះអាងរបស់គូភាគី:**

-មេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ បានធ្វើសេចក្ដីថ្លែងការណ៍ថា: ខ្លួនសូមរក្សាការទាមទាររបស់កូនក្ដីដូចក្នុងពាក្យបណ្ដឹងចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៣ ទុកជាបានការដដែល។

-ចុងចម្លើយឈ្មោះ [redacted] ចាន់នី ធ្វើសេចក្ដីថ្លែងការណ៍៖ ខ្លួនសូមជម្រាបថា ប្ដីខ្លួនឈ្មោះ [redacted] តារាពង្ស ក៏បានទទួលដីកាកោះឱ្យចូលរួមក្នុងនីតិវិធីនេះដែរ តែដោយសារគាត់រវល់មិនអាចចូលរួមបាន ហើយខ្លួនអាចឆ្លើយតំណាងឱ្យប្ដីខ្លួនបានទើបខ្លួនមកឆ្លើយដោយមានមេធាវីតំណាងដោយអាណត្តិ ។

ចំពោះការទាមទាររបស់ដើមចោទត្រង់ចំណុចទី១ ដែលទាមទារឱ្យខ្លួនសងប្រាក់ដើមចំនួន ១៤០,២៨៨.០៤ ដុល្លារអាមេរិក គឺខ្លួនទទួលស្គាល់ការទាមទារនេះ ។

ចំពោះការទាមទាររបស់ដើមចោទត្រង់ចំណុចទី២ ដែលទាមទារឱ្យខ្លួនសងប្រាក់ដើមចំនួន ១៣៩,១៥១.០៩ ដុល្លារអាមេរិក គឺខ្លួនទទួលស្គាល់ការទាមទារនេះ ។

ចំពោះការទាមទាររបស់ដើមចោទត្រង់ចំណុចទី៣ (ការប្រាក់ ១,៥%ក្នុង១ខែ នៃប្រាក់ដើម ១៤០,២៨៨.០៤ ដុល្លារអាមេរិក) ខ្លួនសំណូមពរសូមឱ្យដើមចោទលើកលែងនូវការប្រាក់នេះឱ្យខ្លួនផង ។

ចំពោះការទាមទាររបស់ដើមចោទត្រង់ចំណុចទី៤ (ការប្រាក់ ១,៥%ក្នុង១ខែ នៃប្រាក់ដើម ១៣៩,១៥១.០៩ ដុល្លារអាមេរិក) ខ្លួនសំណូមពរសូមឱ្យដើមចោទលើកលែងនូវការប្រាក់នេះឱ្យខ្លួនផង ។



Scanned with CamScanner

ចំពោះការទាមទាររបស់ដើមចោទត្រង់ចំណុចទី៥ សំណងការខូចខាត រឺការប្រាក់យឺតយ៉ាវ ២៥% ក្នុង០១ឆ្នាំ រាប់គិតពីថ្ងៃទី១៣.០១.២០២៣ (កិច្ចសន្យាចុះថ្ងៃទី១១.០៧.២០២២) រហូតដល់ជម្រះបំណុល ចប់សព្វគ្រប់ ខ្លួនសុំឱ្យដើមចោទលើកលែងឱ្យខ្លួនផង ។

ចំពោះការទាមទាររបស់ដើមចោទត្រង់ចំណុចទី៦ សំណងការខូចខាត រឺការប្រាក់យឺតយ៉ាវ ២៥% ក្នុង០១ឆ្នាំ រាប់គិតពីថ្ងៃទី២៨.០៣.២០២៣ (កិច្ចសន្យាចុះថ្ងៃទី២៦.១២.២០២២) រហូតដល់ជម្រះបំណុល ចប់សព្វគ្រប់ ខ្លួនសុំឱ្យដើមចោទលើកលែងឱ្យខ្លួនផង ។

ចំពោះការទាមទារត្រង់ចំណុចទី៧ សំណងការខូចខាត សេវាកម្មច្បាប់ និងការខូចខាតផ្លូវចិត្ត ចំនួន ៤០,០០០ ដុល្លារអាមេរិក ខ្លួនសូមបដិសេធនូវការទាមទារនេះ ព្រោះចំនួននេះច្រើនពេក ។

-មេធាវី [redacted] ធ្វើសេចក្តីថ្លែងការណ៍៖ ខ្លួនសូមរក្សាសេចក្តីថ្លែងការណ៍របស់កូនក្តីខ្លួន ទុកជាបានការដដែល ។ ខ្លួនសូមបន្ថែមថា ចំពោះការស្នើសុំឱ្យអនុវត្តជាបណ្តោះអាសន្ន មិនបានបញ្ជាក់ត្រង់ ចំណុចណាឱ្យច្បាស់លាស់ មួយវិញទៀតកូនក្តីខ្លួនក៏មានឆន្ទៈដោះស្រាយបំណុល យ៉ាងណាមិញប្រសិនបើ តុលាការប្រកាសឱ្យអនុវត្តបណ្តោះអាសន្ន នឹងធ្វើឱ្យមានឧបសគ្គក្នុងការចាត់ចែងទ្រព្យជានាបំណុលក្នុងការ សងបំណុល ហេតុនេះសូមតុលាការមេត្តាពិចារណាចេញសាលក្រមដែលមិនអាចអនុវត្តជាបណ្តោះអាសន្ន បានដោយមិនមានភាពចាំបាច់ ។ ចំពោះប្រាក់ប្រដាប់ក្តីវិញសុំឱ្យតុលាការសម្រេចដោយឆន្ទានុសិទ្ធិ ។

-មេធាវី [redacted] ធ្វើសេចក្តីថ្លែងការណ៍៖ ចំពោះការសុំឱ្យលើកលែងការប្រាក់ត្រង់ចំណុចទី៣ ទី៤ និងសំណងការខូចខាតចំណុចទី៥ ទី៦ ខ្លួនសុំធ្វើការបដិសេធដោយហេតុថា មានចែងក្នុងកិច្ចសន្យាច្បាស់ លាស់ និងកំណត់ដោយច្បាប់ ។ ចំពោះចំណុចទី៧ សុំតុលាការពិចារណា ព្រោះកូនក្តីខ្លួនមានការខាតបង់ ច្រើន ខ្លួននៅតែស្នើសុំឱ្យមានការអនុវត្តជាបណ្តោះអាសន្នដដែល ព្រោះនេះជាការទាមទារគោលបំណងសង ជាប្រាក់ដែលមានទ្រព្យសម្បត្តិអាចអនុវត្តបាន ហើយការទាមទារនេះគឺទាមទារទាំងអស់សម្រាប់ស្នើសុំឱ្យអនុ វត្តជាបណ្តោះអាសន្ន ដែលមិនមែនជាឧបសគ្គក្នុងការដែលកូនបំណុលចាត់ចែងទ្រព្យជានាបានទេ ។

### III- ចំណុចវិវាទ៖

-តើការទាមទាររបស់ដើមចោទនូវការប្រាក់ ១,៥%ក្នុង១ខែ នៃប្រាក់ដើម ១៤០, ២៨៨.០៤ ដុល្លារ អាមេរិក ត្រឹមត្រូវដែររឺទេ ?

-តើការទាមទាររបស់ដើមចោទនូវការប្រាក់ ១,៥%ក្នុង១ខែ នៃប្រាក់ដើម ១៣៩, ១៥១.០៩ ដុល្លារ អាមេរិក ត្រឹមត្រូវដែររឺទេ ?

-តើការទាមទាររបស់ដើមចោទនូវសំណងការខូចខាត រឺការប្រាក់យឺតយ៉ាវ ២៥% ក្នុង០១ឆ្នាំ រាប់គិត ពីថ្ងៃទី១៣.០១.២០២៣ (កិច្ចសន្យាចុះថ្ងៃទី១១.០៧.២០២២) រហូតដល់ជម្រះបំណុលចប់សព្វគ្រប់ត្រឹម ត្រូវដែររឺទេ ?

-តើការទាមទាររបស់ដើមចោទនូវសំណងការខូចខាត រឺការប្រាក់យឺតយ៉ាវ ២៥% ក្នុង០១ឆ្នាំ រាប់គិត ពីថ្ងៃទី២៨.០៣.២០២៣ (កិច្ចសន្យាចុះថ្ងៃទី២៦.១២.២០២២) រហូតដល់ជម្រះបំណុល ចប់សព្វគ្រប់ ត្រឹម ត្រូវដែររឺទេ ?

-តើការទាមសំណងត្រង់ចំណុចទី៧ សំណងការខូចខាត សេវាកម្មច្បាប់ និងការខូចខាតផ្លូវចិត្ត ចំនួន ៤០,០០០ ដុល្លារអាមេរិក ត្រឹមត្រូវដែរទេ ?

-តើការទាមទារត្រង់ចំណុចទី៩ដែលដើមចោទសុំប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នត្រឹមត្រូវដែររឺទេ ?

## សំអាងហេតុ



Scanned with CamScanner

១-ដើមចោទឈ្មោះ [redacted] សុជា បានប្ដឹងទាមទារប្រាក់ពីសហចុងចម្លើយឈ្មោះ [redacted] តារាពង្ស និងប្រពន្ធឈ្មោះ [redacted] ចាន់នី ដោយសំអាងថា សហចុងចម្លើយបានខ្ចីប្រាក់ពីខ្លួនចំនួន ១៥០,០០០(ដប់ប្រាំម៉ឺន) ដុល្លារអាមេរិក នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ និងចំនួន ១៤០,០០០ (ដប់បួនម៉ឺន) ដុល្លារអាមេរិក នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ ដោយមានលក្ខខណ្ឌ អត្រាការប្រាក់ចំនួន ១៨% ក្នុង០១ឆ្នាំ និងសំណងការខូចខាត ២៥% ក្នុងមួយឆ្នាំ រាប់គិតចាប់ពីថ្ងៃមិនបានទូទាត់ប្រាក់ដើម និងការប្រាក់រហូតដល់ថ្ងៃជម្រះបំណុលចប់សព្វគ្រប់ ។ ដោយការខ្ចីនេះ ចុងចម្លើយបានដាក់បញ្ចាំនូវអចលនវត្ថុមួយចំនួន ។ ក្រោយការខ្ចីនេះ សហចុងចម្លើយបានបង់ប្រាក់ឲ្យដើមចោទ ត្រឹមថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ សម្រាប់កម្ចីចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ និងត្រឹមថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ សម្រាប់កម្ចីចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២។ សហចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ចក្នុងការបង់ប្រាក់ដើម និងការប្រាក់ជូនទៅដើមចោទនោះទេ។

២-ដើមចោទទាមទារ ឲ្យសហចុងចម្លើយ សងប្រាក់ដើមចំនួន USD ១៤០,២៨៨.០៤ (ដប់បួនម៉ឺនពីររយប៉ែតសិបប្រាំបីដុល្លារអាមេរិក និងបួនសេន) តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនិងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ ឲ្យសហចុងចម្លើយ សងប្រាក់ដើមចំនួនUSD ១៣៩,១៥១.០៩ (ដប់បីម៉ឺនប្រាំបួនពាន់មួយរយហាសិបមួយ ដុល្លារអាមេរិក និងប្រាំបួនសេន) តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក និងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២។ ចំណែកចុងចម្លើយបានទទួលស្គាល់ការទាមទារនេះ ដូច្នេះ តុលាការយល់ឃើញថា ប្រាក់ដើមដែលសហចុងចម្លើយជំពាក់ដើមចោទគឺពិតជាមានចំនួន USD ១៤០,២៨៨.០៤ (ដប់បួនម៉ឺនពីររយប៉ែតសិបប្រាំបីដុល្លារអាមេរិក និងបួនសេន) ដែលខ្ចីកាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ និងចំនួនUSD ១៣៩,១៥១.០៩ (ដប់បីម៉ឺនប្រាំបួនពាន់មួយរយហាសិបមួយ ដុល្លារអាមេរិក និងប្រាំបួនសេន) ដែលខ្ចីកាលពីថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ ពិតប្រាកដមែន ។

៣-ដើមចោទទាមទារឲ្យសហចុងចម្លើយ សងការប្រាក់ ១,៥% ក្នុងមួយខែ លើប្រាក់ដើមចំនួន USD ១៤០,២៨៨.០៤(ដប់បួនម៉ឺនពីររយប៉ែតសិបប្រាំបី ដុល្លារអាមេរិក និងបួនសេន) គិតត្រឹមពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួន ទៅឲ្យដើមចោទ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនិងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ និងលើប្រាក់ដើមចំនួន USD ១៣៩,១៥១.០៩(ដប់បីម៉ឺនប្រាំបួនពាន់មួយរយហាសិបមួយ ដុល្លារអាមេរិក និងប្រាំបួនសេន) គិតត្រឹមពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួន ទៅឲ្យដើមចោទ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក និងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ ការទាមទារនេះត្រូវបានចុងចម្លើយសុំឱ្យលើកលែងនូវការទូទាត់ការប្រាក់នេះឱ្យខ្លួនផង ប៉ុន្តែត្រូវបានដើមចោទបដិសេធចោល ដោយយល់ថា ការទាមទារនេះមានចែងក្នុងកិច្ចសន្យាច្បាស់លាស់។

យោងទៅលើកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ និងចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ ឃើញថា ពិតជាបានកំណត់អត្រាការប្រាក់ចំនួន ១៨% ក្នុង០១ឆ្នាំ ឬស្មើនឹង ១,៥% ក្នុង០១ខែ ពិតប្រាកដមែន ។



Scanned with CamScanner

តាមប្រកាសស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិតលេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១ របស់ក្រសួងយុត្តិធម៌ ត្រង់សេចក្តីសម្រេច ប្រការ១ ចែងថា អត្រាការប្រាក់ដែលត្រូវបានកម្រិតដែលបានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា ១៧ (អត្រាការប្រាក់ដែលត្រូវបានកម្រិតជាអាទ៍) នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ត្រូវបានកំណត់មិនឱ្យលើសពី ១៨% (ដប់ប្រាំបីភាគរយ) ក្នុង០១ឆ្នាំ។ ដូច្នេះ ការកំណត់អត្រាការប្រាក់ ១៨% ក្នុង០១ឆ្នាំ ឬស្មើនឹង១,៥% ក្នុង០១ខែ នៅក្នុងកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ និងចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២ ឃើញថា ជាចំនួនអត្រាការប្រាក់ដែលស្ថិតនៅក្នុងការកំណត់របស់ច្បាប់ តុលាការអាចយកមកពិចារណាសម្រេចបាន ។

៤-ដើមចោទទាមទារឲ្យសហចុងចម្លើយ សងសំណងការខូចខាត ២៥% ក្នុងមួយឆ្នាំ រាប់គិតចាប់ពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃជម្រះបំណុលចប់សព្វគ្រប់ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនិងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ និងរាប់គិតចាប់ពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃជម្រះបំណុលចប់សព្វគ្រប់ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតកនិងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២។ ការទាមទារនេះត្រូវបានចុងចម្លើយសុំឱ្យដើមចោទលើកលែងឱ្យខ្លួនផង ប៉ុន្តែត្រូវបានដើមចោទបដិសេធចោល ដោយយល់ថា ការទាមទារនេះមានចែងក្នុងកិច្ចសន្យាច្បាស់លាស់ ។

ឃើញថា ភាគីនៃកិច្ចសន្យាខ្ចីបរិភោគទាំងពីរខាងលើ មានសមត្ថភាពខាងធនុះគ្រប់គ្រាន់ក្នុងការបង្កើតកិច្ចសន្យា និងមិនមែនជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពឡើយ ហើយកិច្ចសន្យានេះទៀតសោត ក៏ធ្វើឡើងដោយការព្រមព្រៀងរវាងអ្នកខ្ចី និងអ្នកឱ្យខ្ចីស្របតាមបញ្ញត្តិមាត្រា ៥៧៩ នៃក្រមរដ្ឋប្បវេណី ដោយគ្មានការបង្ខិតបង្ខំ ការក្លែងបន្លំ ឬមានវិការៈអ្វីឡើយ ដូច្នេះ ការកំណត់សងសំណងការខូចខាត ២៥% ក្នុងមួយឆ្នាំ ជាធនុះរបស់គូភាគីដែលបានព្រមព្រៀងគ្នាតាំងពីដើមមក។ កិច្ចសន្យាមានអានុភាពក្នុងការបង្កើតនូវទំនាក់ទំនងគតិយុត្តរវាងអ្នកខ្ចី និងអ្នកឱ្យខ្ចីដែលភាគីទាំងពីរមានកាតព្វកិច្ចត្រូវតែអនុវត្តតាមការព្រមព្រៀងនេះ ដូច្នេះ តុលាការគប្បីសម្រេចទៅតាមការកំណត់នៃកិច្ចសន្យានេះ ។

៥-ដើមចោទទាមទារឱ្យសហចុងចម្លើយសងសំណងនៃការខូចខាត សេវាកម្មច្បាប់ និងការខូចខាតផ្លូវចិត្ត ចំនួន USD ៤០,០០០ (បួនម៉ឺនដុល្លារអាមេរិកគត់) ប៉ុន្តែចុងចម្លើយបដិសេធចំពោះការទាមទារនេះព្រោះចំនួននេះច្រើនពេក ។ តុលាការយល់ឃើញថា នៅក្នុងកិច្ចសន្យាខ្ចីបរិភោគខាងលើ បានកំណត់អំពីសងសំណងការខូចខាត ២៥% ក្នុងមួយឆ្នាំរួចហើយ ។ ចំនួននេះគឺធួនល្មមនឹងការជួសជុលនូវព្យសនកម្មដែលដើមចោទបានទទួលរងហើយ ដូច្នេះ តុលាការគប្បីច្រានចោលការទាមទារចំពោះការស្នើសុំរបស់ដើមចោទដែលទាមទារសំណងនៃការខូចខាត សេវាកម្មច្បាប់ និងការខូចខាតផ្លូវចិត្ត ចំនួន USD ៤០,០០០ (បួនម៉ឺនដុល្លារអាមេរិកគត់) ពីចុងចម្លើយ ។

៦-ដើមចោទបានស្នើសុំប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្នចំពោះការទាមទារខាងលើ ប៉ុន្តែភាគីខាងចុងចម្លើយបានបដិសេធដោយអះអាងថាៈ ការស្នើសុំឱ្យអនុវត្តជាបណ្តោះអាសន្នមិនបានបញ្ជាក់ត្រង់ចំណុចណាឱ្យច្បាស់លាស់ មួយវិញទៀតកូនក្តីខ្លួនក៏មានធនុះដោះស្រាយបំណុល យ៉ាងណាមិញប្រសិនបើ



Scanned with CamScanner

តុលាការប្រកាសឱ្យអនុវត្តបណ្ដោះអាសន្ន នឹងធ្វើឱ្យមានឧបសគ្គក្នុងការចាត់ចែងទ្រព្យជានាបំណុលក្នុងការសងបំណុល ហេតុនេះសូមតុលាការមេត្តាពិចារណាចេញសាលក្រមដែលមិនអាចអនុវត្តជាបណ្ដោះអាសន្នបានដោយមិនមានភាពចាំបាច់ ។

តុលាការយល់ឃើញថា ការទាមទាររបស់ដើមចោទជាការទាមទារលើទ្រព្យសម្បត្តិ និងដោយមានភាពចាំបាច់ដើម្បីការពារនូវផលប្រយោជន៍របស់ដើមចោទ ហើយចុងចម្លើយក៏បានទទួលស្គាល់ប្រាក់ដើមដែលជំពាក់ដើមចោទចំនួន USD ១៤០,២៨៨.០៤(ដប់បួនម៉ឺនពីររយប៉ែតសិបប្រាំបីដុល្លារអាមេរិក និងបួនសេន) ដែលមាននៅក្នុងកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២ និងចំនួន USD ១៣៩,១៥១.០៩ (ដប់បីម៉ឺនប្រាំបួនពាន់មួយរយហាសិបមួយ ដុល្លារអាមេរិក និងប្រាំបួនសេន) តាមរយៈកិច្ចសន្យាខ្ចីបរិភោគចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២។ ដូច្នេះ គប្បីតុលាការប្រកាសអនុវត្តជាបណ្ដោះអាសន្ន ដោយយោងតាមមាត្រា ១៩៦ កថាខណ្ឌ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

៧-ចំពោះប្រាក់ប្រដាប់ក្ដីវិញ ដោយយោងតាមក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា៦៤ កថាខណ្ឌ១ ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីចាញ់ក្ដី ។

## <u>សេចក្ដីសម្រេចបញ្ចប់</u>

១- ឱ្យសហចុងចម្លើយឈ្មោះ [redacted] តារាពង្ស និងប្រពន្ធឈ្មោះ [redacted] ចាន់នី ត្រូវសងប្រាក់កម្ចីឲ្យទៅដើមចោទឈ្មោះ [redacted] សុជា ភេទប្រុស ជាតិខ្មែរ អាសយដ្ឋានស្ថិតនៅផ្ទះលេខ [redacted] នូវទឹកប្រាក់ ដូចខាងក្រោម ៖

១.១. បង្គាប់ឲ្យសហចុងចម្លើយ សងប្រាក់ដើមចំនួន USD ១៤០,២៨៨.០៤ (ដប់បួនម៉ឺនពីររយប៉ែតសិបប្រាំបីដុល្លារអាមេរិក និងបួនសេន) ទៅឲ្យដើមចោទ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនិងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២។

១.២. បង្គាប់ឲ្យ សហចុងចម្លើយ សងប្រាក់ដើមចំនួន USD ១៣៩,១៥១.០៩ (ដប់បីម៉ឺនប្រាំបួនពាន់មួយរយហាសិបមួយ ដុល្លារអាមេរិក និងប្រាំបួនសេន) ទៅឲ្យដើមចោទ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក និងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២។

១.៣. បង្គាប់ឲ្យ សហចុងចម្លើយសងការប្រាក់ ១,៥% ក្នុងមួយខែ លើប្រាក់ដើមចំនួន USD ១៤០,២៨៨.០៤(ដប់បួនម៉ឺនពីររយប៉ែតសិបប្រាំបី ដុល្លារអាមេរិក និងបួនសេន) គិតត្រឹមពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួនទៅឲ្យដើមចោទ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនិងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២។

១.៤. បង្គាប់ឲ្យ សហចុងចម្លើយ សងការប្រាក់ ១,៥% ក្នុងមួយខែ លើប្រាក់ដើមចំនួន USD ១៣៤,១៥១.០៩(ដប់បីម៉ឺនប្រាំបួនពាន់មួយរយហាសិបមួយ ដុល្លារអាមេរិក និងប្រាំបួនសេន) គិតត្រឹមពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងប្រាក់ដើមគ្រប់ចំនួនទៅឲ្យដើមចោទ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក និងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២។



Scanned with CamScanner

១.៥.បង្គាប់ឲ្យ សហចុងចម្លើយ សងសំណងការខូចខាត ២៥% ក្នុងមួយឆ្នាំ រាប់គិតចាប់ពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃជម្រះបំណុលចប់សព្វគ្រប់ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនិងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២។

១.៦. បង្គាប់ឲ្យ សហចុងចម្លើយ សងសំណងការខូចខាត ២៥% ក្នុងមួយឆ្នាំ រាប់គិតចាប់ពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ រហូតដល់ថ្ងៃជម្រះបំណុលចប់សព្វគ្រប់ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតកនិងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២។

២-ច្រានចោលការទាមទារត្រង់ចំណុចទី៧ ដែលដើមចោទទាមទារឱ្យសហចុងចម្លើយ សងសំណងនៃការខូចខាត សេវាកម្មច្បាប់ និងការខូចខាតផ្លូវចិត្តឲ្យមក ដើមចោទ ចំនួន USD ៤០,០០០ (បួនម៉ឺនដុល្លារអាមេរិកគត់)។

៣- សាលក្រមនេះអាចអនុវត្តជាបណ្តោះអាសន្នបាន ត្រង់៖

ចំណុចទី: ១.១. (បង្គាប់ឲ្យសហចុងចម្លើយ សងប្រាក់ដើមចំនួន USD ១៤០,២៨៨.០៤ (ដប់បួនម៉ឺនពីររយប៉ែតសិបប្រាំបីដុល្លារអាមេរិក និងបួនសេន) ទៅឲ្យដើមចោទ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែកនិងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២២។

ចំណុចទី: ១.២. (បង្គាប់ឲ្យ សហចុងចម្លើយ សងប្រាក់ដើមចំនួន USD ១៣៩,១៥១.០៩ (ដប់បីម៉ឺនប្រាំបួនពាន់មួយរយហាសិបមួយ ដុល្លារអាមេរិក និងប្រាំបួនសេន) ទៅឲ្យដើមចោទ តាមរយៈកិច្ចសន្យាខ្ចីបរិភោគ និងកិច្ចសន្យាបង្កើតហ៊ីប៉ូតែក និងឧបសម្ព័ន្ធ "ក" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២២។

៤- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

៥- សាលក្រមនេះ ប្រកាសជាសាធារណៈចំពោះមុខ ភាគីដើមចោទ និងភាគីសហចុងចម្លើយ ។

- ទុកសិទ្ធិឲ្យដើមចោទ និងចុងចម្លើយប្តឹងឧទ្ធរណ៍រយៈពេល០១ខែ គិតចាប់ពីថ្ងៃបានទទួលអនុសារៈសាលក្រមនេះ ។

**ចៅក្រម**

ហត្ថលេខា និងត្រា: [redacted]

---

"បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ១រោច ខែចែត្រ ឆ្នាំរោង ឆស័ក ព.ស ២៥៦៧

កណ្តាល ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៤

បានឃើញ

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner